


# Education អប់រំ
# បច្ចេកវិទ្យា Technology

សាលាអាមេរិកាំង ស្ទែនហ្វដ
STANFORD American School
Excel your language
ភាសា អង់គ្លេស ចិន ថៃ កុំព្យូទ័រ
វគ្គថ្មី ២០ មិថុនា ២០១៦
ទទួលចុះឈ្មោះត្រឹមថ្ងៃទី ១៥ មិថុនា ២០១៦
069 668 758/012 956 357 | អគារ ១៩៧ ផ្លូវ ១៩៦ សន្ធរមុខ



HongLeong Bank
1.68% p.a basic interest rate + 0.25% p.a bonus interest rate
គណនីប្រាក់សន្សំសម្រាប់កុមារ
បណ្តុះទម្លាប់សន្សំប្រាក់តាំងពីវ័យកុមារ
1.93% p.a total interest rate
023 999 711
www.hlb.com.kh

## JAGUARF-PACE បង្ហាញខ្លួនប្រជែងទីផ្សាររថយន្តប្រភេទ SUV នៅកម្ពុជា



អាននៅទំព័រ(26)

## មជ្ឈមណ្ឌលសិក្សាពីចម្ងាយ ផ្សព្វផ្សាយ និងលើកកម្ពស់ការសិក្សាបែបE-learning



អាននៅទំព័រ(24)

## គុណសម្បត្តិ និងគុណវិបត្តិនៃការប្រើប្រាស់បណ្តាញសង្គមហ្វេសប៊ុក




បច្ចុប្បន្នការប្រើបណ្តាញសង្គមហ្វេសប៊ុក(Facebook) កំពុងមានភាពពេញនិយមយ៉ាងខ្លាំង ក្នុងការទំនាក់ទំនងរបស់មនុស្សគ្រប់ស្រទាប់ពិសេសស្រទាប់យុវវ័យ ប៉ុន្តែយ៉ាងណានោះ ការប្រើប្រាស់ហ្វេសប៊ុក អាចបង្កឱ្យមានគុណសម្បត្តិផងនិងគុណវិបត្តិផង អាស្រ័យទៅលើការប្រើប្រាស់របស់មនុស្សម្នាក់ៗ។

លោក ប៉ែន បូណា ប្រធានក្លិបអ្នកកាសែតកម្ពុជាមានប្រសាសន៍ថា ក្រមសីលធម៌នៃការប្រើប្រាស់បណ្តាញសង្គមហ្វេសប៊ុក គឺមានសារៈសំខាន់ណាស់ ដោយសារតែប្រព័ន្ធសង្គមហ្វេសប៊ុកនេះមានមហាជនទូទៅ កំពុងតែប្រើប្រាស់និងបញ្ចេញមតិ ទំនាក់ទំនងរវាងគ្នា និងគ្នា ឬទំនាក់ទំនងរវាងប្រជាជននិងរដ្ឋាភិបាល។ តែការប្រើប្រាស់ហ្វេសប៊ុកអាចបញ្ជូនសារ និងទិន្នន័យបានលឿនប្រាកដមែន ប៉ុន្តែភាគច្រើន អាចជាព័ត៌មានមិនពិត មិនច្បាស់លាស់ និងមិនអាចយកធ្វើជាផ្លូវការបាន រហូតធ្វើឱ្យក្លាយជាព័ត៌មាន បំពុល...តទៅទំព័រ(23)

## Huawei ក្លាយជាក្រុមហ៊ុនផលិតស្មាតហ្វូនប្រើប្រព័ន្ធ Android ដែលទទួលបានប្រាក់ចំណេញខ្ពស់ជាងគេ




អាននៅទំព័រ(27)

# បើមិនបង្កើនការអានប្រជាជនខ្មែរយើងនៅតែមិនមានភាពចាស់ទុំ



លោក ហេង ស្រ៊ាង



លោក ឈិន សីហា



លោក ឡុច ចន្ថា

ដោយសារតែប្រជាជនខ្មែរមិនសូវមានគំនិតចាស់ទុំ បញ្ហាជាច្រើនដូចជាបញ្ហាចរាចរណ៍ អំពើហិង្សា ការប្រើសម្ដីមិនសមរម្យ និងគំរូមិនល្អមួយចំនួនទៀតបានកើតឡើងជារៀងរាល់ថ្ងៃនៅក្នុងប្រទេស។ ការអានត្រូវបានរកឃើញថាជាវិធីយ៉ាងប្រសើរមួយដើម្បីដោះស្រាយទម្លាប់មិនល្អក្នុងសង្គម ហើយបង្កើតទម្លាប់ល្អផ្នែកផ្លូវចិត្ត និងកាយវិការក្នុងការរស់នៅប្រចាំថ្ងៃនៅកម្ពុជា។

សាស្ត្រាចារ្យទស្សនវិជ្ជា និងជាប្រធានសមាគមប៊ិកកម្ពុជា លោក ហេង ស្រ៊ាង បានលើកឡើងថា បញ្ហាសំខាន់មួយដែលប្រជាជនខ្មែរកំពុងតែជួបប្រទះគឺការអប់រំនៅមានកម្រិតនៅឡើយ ហើយទម្លាប់អានរបស់ប្រជាជនខ្មែរមានចំនួនតិចតួចដោយសារតែមិនសូវមានសកម្មភាពលើកកម្ពស់ការអាន។ ដោយសារតែប្រជាជនខ្មែរមិនសូវចូលចិត្តអាន ធ្វើឱ្យពួកគេមិនយល់ដឹងពីផលអវិជ្ជមាននៃសកម្មភាពដែលខ្លួនបានធ្វើឡើង។ ពួកគេងាយសម្រេចចិត្ត និងប្រព្រឹត្តអំពើអ្វីមួយខុសដោយងាយ ដូចជាការបង្ហាញចរិតហិង្សា ឬការរំលោភច្បាប់ជាដើម។ នៅចំពោះមុខ សង្គមត្រូវការលើកកម្ពស់កត្តាមួយចំនួនជាចាំបាច់ គឺការអាន ការអប់រំ និងច្បាប់។

លោក ហេង ស្រ៊ាង បានមានប្រសាសន៍ថា៖ “ការអានច្រើន នឹងធ្វើឱ្យមនុស្សចេះច្រើន យល់ដឹងច្រើន ដែលជំរុញឱ្យពួកគេអាចប្រើវិចារណញ្ញាណបានល្អក្នុងការរស់នៅ ហើយអាចដោះស្រាយបញ្ហាដោយផ្អែកលើការគិតពិចារណាស៊ីជម្រៅមានហេតុផល និងបញ្ចេញសកម្មភាពប្រកបដោយសន្តិភាព”។

លោក ហេង ស្រ៊ាង បានបន្ថែមទៀតថា ដើម្បីឱ្យប្រជាជនខ្មែរមានភាពចាស់ទុំ និងចូលរួមចំណែកបានល្អនៅក្នុងការអភិវឌ្ឍសង្គម ពួកគេគួរតែអានសំណេរទូទៅ ឬសំណេរទាំងឡាយណាដែលអាចផ្ដល់ការគិតពិចារណាបានដូចជាឯកសារអក្សរសាស្ត្រ កំណាព្យ រឿងប្រលោមលោកអប់រំ សៀវភៅទស្សនវិជ្ជា និងបទវិភាគផ្សេងៗ។ លើសពីនេះទៅទៀតពួកគេគួរតែស្វែងរកឯកសារ ឬអានពីច្បាប់របស់សង្គមឱ្យបានច្រើនដើម្បីងាយស្រួលដល់ការគោរព និងផ្សព្វផ្សាយបន្តដល់បុគ្គលដទៃទៀតដែលរស់នៅក្នុងសង្គមជាមួយគ្នា។

ជុំវិញបញ្ហានៃការអាន និងស្ថានភាពរបស់ប្រជាជនកម្ពុជានេះ លោក ឡុច ចន្ថា អ្នកនិពន្ធ និងជាផលិតករកម្មវិធីជំនួបអ្នកនិពន្ធនៅកម្ពុជា បានលើកឡើងថា ជាការកត់សម្គាល់ លោកឃើញថាបុគ្គលដែលមិនចូលចិត្តអានភាគច្រើនជាអ្នកចូលចិត្តប្រើហិង្សា ដោយសារតែបុគ្គលទាំងអស់នោះមិនសូវបានអប់រំខ្លួនឯង។ តែសម្រាប់អ្នកដែលបានអានច្រើនវិញគឺគាត់អាចអប់រំផ្លូវចិត្តបានល្អ មានឱកាសអប់រំសីលធម៌ ទទួលយកការកែប្រែឥរិយាបថឱ្យកាន់តែប្រសើរឡើង ចេះគ្រប់គ្រងខ្លួនឯងបានល្អ និងមានភាពបត់បែនក្នុងការរស់នៅ។

ជាក់ស្ដែង ជាការមើលឃើញ គឺប្រជាជនដែលមិនសូវអានគាត់មិនសូវគោរពច្បាប់ចរាចរណ៍ ដោយស្ថានភាពខ្លះគាត់ខុសដោយមិនដឹងខ្លួន។ ចំណែកឯបញ្ហាមួយចំនួនទៀតក៏កើតចេញពីការដែលបុគ្គលម្នាក់ៗមិនព្យាយាមស្វែងយល់ពីខ្លួនឯង ឬរកមិនឃើញពីវិធីដែលអាចរស់នៅប្រកបដោយសេចក្ដីសុខ ដោយសារតែពួកគាត់មិនបានអាន។

លោក ឡុច ចន្ថា បានមានប្រសាសន៍ថា៖ “បញ្ហាចម្បងនានានៅក្នុងសង្គម អាចនឹងត្រូវទប់ស្កាត់បានប្រសិនបើប្រជាជនភាគច្រើនបានអាន ហើយអប់រំចិត្តបានល្អ តែចំណុចប្រឈមដែលយើងមានគឺមិនទាន់មានការបំផុសការអានឱ្យបានគ្រប់គ្រាន់នៅឡើយ។ ស្ថាប័នរដ្ឋ និងឯកជនមិនទាន់បានផ្សព្វផ្សាយ ឬណែនាំប្រជាជនឱ្យស្គាល់ពីតម្លៃនៃការអាន ហើយឯកសារសម្រាប់អានទៀតសោតក៏នៅមានកម្រិតនៅឡើយ”។

លោក ចន្ថា ណែនាំថា ប្រជាជនខ្មែរគួរចាប់អារម្មណ៍លើការអានឯកសារទាំងឡាយណាដែលមានប្រយោជន៍សម្រាប់ការរស់នៅដោយចាប់ផ្ដើមពីការស្វែងយល់ពីវប្បធម៌ និងប្រវត្តិសាស្ត្រដើម្បីស្គាល់ឱ្យច្បាស់ថាខ្លួនជាអ្នកណា។ បន្ទាប់មកឈានមួយជំហានទៀតទៅស្វែងយល់ពីចំណេះដឹងខាងក្រៅដូចជាបែបបទក្នុងអាស៊ាន អរិយធម៌នៃប្រទេសនានាដែលអាចរៀនសូត្របាន ឬស្វែងយល់ពីការចូលរួមចំណែកអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងសន្តិភាពសង្គមជាដើម។

ក្រៅពីនេះអ្នកនិពន្ធខាងលើបានបន្ថែមទៀតថា ប្រជាជនខ្មែរគួរព្យាយាមរកសៀវភៅណាដែលអាចដុះខាត់ខួរក្បាលខ្លួនឯងឱ្យមានទស្សនវែងឆ្ងាយ និងមានការគិតបានល្អិតល្អន់ ដូចជាសៀវភៅទស្សនវិទ្យាជាដើម។ ប្រជាជនខ្មែរក៏គួរតែអានឯកសារទាក់ទងនឹងការអប់រំចិត្តសាស្ត្រដើម្បីអប់រំចិត្តក្រោធរបស់ខ្លួន អប់រំពីការដោះស្រាយអារម្មណ៍ស្ត្រេស អប់រំសីលធម៌ និងការរៀនរស់ជាមួយអ្នកដទៃជាដើម។ ចុងក្រោយលោកស្នើសុំឱ្យប្រជាជនខ្មែរគួរអានអត្ថបទសារព័ត៌មានឱ្យបានច្រើនដើម្បីតាមដានឱ្យដឹងពីស្ថានភាពសង្គមនាពេលបច្ចុប្បន្ន ដូចជាការប្រែប្រួលនៃសេដ្ឋកិច្ចសង្គម ដើម្បីងាយរកស៊ី ឬដើម្បីរស់នៅប្រកបដោយតម្លៃក្នុងសង្គម ស្របតាមរបត់នយោបាយ សេដ្ឋកិច្ច និងសង្គម។

អ្នកស្រាវជ្រាវ និងជាអ្នកនិពន្ធវ័យក្មេង លោក ឈិនសីហាបានលើកឡើងថាការមិនទម្លាប់អានស្ទើរតែក្លាយជាវប្បធម៌មួយរបស់ប្រជាជនខ្មែរទូទៅមួយចំនួនទៅហើយ។ កត្តានេះបានធ្វើឱ្យគុណភាពនៃការគិតរបស់ប្រជាជនមានភាពទន់ខ្សោយ និងធ្វើសកម្មភាពអ្វីមួយដោយមិនមានហេតុផលច្រើន។

លោក ឈិន សីហា បាននិយាយថា៖ “ការអានធ្វើឱ្យមនុស្សចាស់ទុំលើផ្នត់គំនិត ការនិយាយស្ដី ការធ្វើការងារ ការជជែកពិភាក្សា និងមានស្មារតីប្រុងប្រយ័ត្នលើរាល់សកម្មភាពប្រកបដោយពុទ្ធិខ្ពង់ខ្ពស់ក្នុងការរស់នៅ។ ហេតុនេះការអានជាវិធីល្អបំផុតក្នុងការអភិវឌ្ឍសមត្ថភាពនៃការគិតរបស់ប្រជាជនកម្ពុជា ហើយបញ្ចប់រាល់បញ្ហានានាមួយចំនួនធំដែលធ្លាប់កើតមានក្នុងសង្គម”។

បើតាមលោក ឈិន សីហា ប្រជាជនខ្មែរគួរចាប់ផ្ដើមសម្លឹងមើលឯកសារនានាដើម្បីចាប់ផ្ដើម បណ្ដុះគំនិតអាន និងបន្តទម្លាប់ល្អនេះទៅអ្នកជំនាន់ក្រោយតាមរយៈការអប់រំក្មេងៗឱ្យយល់ដឹងពីសារសំខាន់នៃការអានក្នុងជីវិត និងសង្គម៕



# គុណសម្បត្តិ និងគុណវិបត្តិនៃការប្រើប្រាស់បណ្តាញ...

តពីទំព័រ(21)...បរិយាកាសដល់ប្រព័ន្ធផ្សព្វផ្សាយអាជីព នៅក្នុងប្រទេសកម្ពុជា និងប៉ះពាល់ទៅដល់ព័ត៌មានអាជីពទៀតផង ដែលអ្នកប្រើប្រាស់គួរតែគិតគូរ និងប្រើវាដើម្បីជាអត្ថប្រយោជន៍របស់ខ្លួននិងសង្គមទាំងមូល។

លោក Rene Gradwohl ប្រធានមូលនិធិខុនរ៉ាដអាដេណៅអ៊ែរ មានប្រសាសន៍ថាការប្រើប្រាស់ប្រព័ន្ធសង្គមហ្វេសប៊ុកកំពុងមានប្រជាប្រិយភាព មិនថានៅប្រទេសកម្ពុជា ឬនៅប្រទេសផ្សេងលើពិភពលោកនោះទេ ហើយថាមនុស្ស2ភាគ3នៅលើពិភពលោក កំពុងទទួលយកព័ត៌មានតាមរយៈបណ្តាញសង្គមហ្វេសប៊ុក ហើយពួកគេយល់ថាជាព័ត៌មានត្រឹមត្រូវថែមទៀត។


លោក ប៉ែន បូណា


ឯកឧត្តម ខៀវ កាញារីទ្ធ


លោក Rene Gradwohl

លោកថាហ្វេសប៊ុកមានភាពវិជ្ជមានក្នុងការប្រាស្រ័យទាក់ទងរវាងប្រជាជននិងអ្នកនយោបាយនិងរិះគន់អ្នកនយោបាយដែលប្រើសម្តីកាយវិការមិនសមរម្យប៉ុន្តែយ៉ាងណានោះព័ត៌មាននេះនៅមិនទាន់មានប្រព័ន្ធCheck&Balanceនោះទេដែលជាហេតុធ្វើឱ្យព័ត៌មានមិនអាចទាន់យកជាផ្លូវការបាននៅឡើយ ដែលជាហេតុធ្វើឱ្យវាក្លាយជាព័ត៌មានបំពុលក្នុងសង្គម នីមួយៗទៀតផង ជួនកាលវាបានពង្រីកវិសាលភាព នៃភាពអវិជ្ជមានយ៉ាងខ្លាំងនៅក្នុងសង្គម និងបែងចែកគំនិតប្រកួតប្រជែងផ្សេងៗគ្នា ដូច្នេះអ្វីដែលយើងត្រូវការគឺការជជែកពិភាក្សាគ្នាផ្លាស់ប្តូរគំនិតស្វែងរកគោលការណ៍ល្អ ដើម្បីឱ្យការប្រើប្រាស់ហ្វេសប៊ុកមានភាពប្រសើរ ប្រែក្លាយប្រព័ន្ធនេះឱ្យផ្តល់នូវព័ត៌មានពិត សម្រាប់លើកស្ទួយប្រយោជន៍ក្នុងសង្គម។

ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន មានប្រសាសន៍ដែរថា ព័ត៌មាននៅតាមបណ្តាញសង្គមហ្វេសប៊ុក ជាព័ត៌មានពាក់កណ្តាលសម្រេច ដែលមិនអាចយកជាផ្លូវការបាន100ភាគរយទេ ដោយសារវាបានផ្តល់ព័ត៌មានលឿនពេក មិនអាចវិភាគស្ថានការណ៍បានគ្រប់ជ្រុងជ្រោយ។ បើប្រៀបធៀបរវាងព័ត៌មានអេឡិចត្រូនិក និងព័ត៌មានបោះពុម្ពផ្សាយមានភាពប្រសើរល្អម្យ៉ាងម្នាក់ មួយលឿន ប៉ុន្តែមួយទៀតបោះពុម្ពផ្សាយផ្តល់ព័ត៌មានពិត អាចយកជាផ្លូវការបាន។

ឯកឧត្តមបន្តថា ការប្រើប្រាស់បណ្តាញសង្គមហ្វេសប៊ុកបានផ្តល់ព័ត៌មានលឿន ប៉ុន្តែវាបានធ្វើឱ្យប៉ះពាល់ដល់ក្រមសីលធម៌ និងវិជ្ជាជីវៈ និងពេលខ្លះអាចជាការដាក់ទោសមនុស្សទៀតផង។ ឯកឧត្តមលើកជាឧទាហរណ៍ថា ក្មេងស្រីជនបរទេសអាយុ12ឆ្នាំម្នាក់ ដោយសារទុកចិត្តមិត្តភក្តិនាងបានដោះអាវឱ្យសង្សារមើលតាមហ្វេសប៊ុកហើយសង្សាបានយករូបនោះទៅបង្ហោះ ធ្វើឱ្យក្មេងស្រីនោះខ្មាសគេ ដូរពីសាលាពីមួយទៅសាលាអស់3ទៅ4សាលា ហើយ គេនៅតែបន្តបង្ហោះរូបនោះធ្វើឱ្យនាងឈឺចិត្តចុងក្រោយសម្លាប់ខ្លួននៅអាយុ15ឆ្នាំ ដែលនេះជាការដាក់ទោស ធ្វើឱ្យមនុស្សស្លាប់ដោយសារការប្រើហ្វេសប៊ុកមិនបានត្រឹមត្រូវ។




ឯកឧត្តមបញ្ជាក់ថា ហ្វេសប៊ុកបានផ្តល់ព័ត៌មានលឿន ប៉ុន្តែអ្នកប្រើប្រាស់ត្រូវគិតពីក្រមសីលធម៌ និងវិជ្ជាជីវៈក្នុងការប្រើប្រាស់ ដើម្បីជាប្រយោជន៍សម្រាប់ការបំពេញការងារផ្សេងៗរបស់ខ្លួន ជៀសវាងផលប៉ះពាល់លើខ្លួនឯង អ្នកដទៃ និងសង្គមជាតិទាំងមូល៕

# ប្រជាជនខ្មែរជាង៦ម៉ឺននាក់កំពុងប្រឈមមុខខ្ពស់ជាមួយមេរោគអេដស៍

គណៈកម្មាធិការសម្របសម្រួលប្រយុទ្ធនឹងជំងឺអេដស៍បានបង្ហាញថា ស្ត្រីបម្រើការនៅតាមគ្រឹះស្ថានកម្សាន្តសប្បាយ បុរសរួមភេទជាមួយបុរស អ្នកបំប្លែងភេទ និងអ្នកចាក់ថ្នាំញៀនសរុបចំនួន 62,043 នាក់ ឬស្មើនឹង 77% នៃចំនួនប៉ាន់ប្រមាណសរុបក្រុមប្រឈមមុខខ្ពស់នៅប្រទេសកម្ពុជា ខណៈដែលចំនួន 59% បានទទួល ការអប់រំ និងធ្វើតេស្តឈាម ដោយក្រុមអ្នកស័គ្រចិត្តនៅតាមសហគមន៍នៃអង្គការមិនមែនរដ្ឋាភិបាល។

លោក ជូប សុខចំរើន នាយកប្រតិបត្តិអង្គការខាណា ប្រធានគណៈកម្មាធិការសម្របសម្រួលប្រយុទ្ធនឹងជំងឺអេដស៍ និងជាតំណាងអង្គការសង្គមស៊ីវិលកំពុងអនុវត្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍បានថ្លែងថា សម្រាប់រយៈពេល 12ខែនៃឆ្នាំ 2015-2016 នេះ អង្គការខាណា និងអង្គការដៃគូដែលអនុវត្តគម្រោងផ្ទាល់នៅតាមសហគមន៍ ក្នុងរាជធានី-ខេត្តទាំង 23 ក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) និងតាមរយៈគម្រោងមូលនិធិសកលប្រយុទ្ធនឹងជំងឺអេដស៍ របេង និងគ្រុនចាញ់ (GFATM) បានធ្វើសកម្មភាពផ្តល់ការអប់រំ និងផ្តល់មធ្យោបាយបង្ការមេរោគអេដស៍ដល់ក្រុមគោលដៅប្រឈមមុខខ្ពស់គ្រប់ ប្រភេទ រួមមានស្ត្រីបម្រើការនៅតាមតំបន់កម្សាន្តសប្បាយ បុរសរួមភេទជាមួយបុរស អ្នកបំប្លែងភេទ និងអ្នកចាក់ គ្រឿងញៀន ប្រហែលជា 77% នៃចំនួនប៉ាន់ប្រមាណសរុបក្រុមប្រឈមមុខខ្ពស់នៅប្រទេសកម្ពុជា។



លោកបន្តថាក្នុងចំនួនដែលបានទទួលការអប់រំនេះ 59%នៃពួកគេបានទទួលយកការធ្វើតេស្តឈាម ដែលធ្វើដោយក្រុមអ្នកស្ម័គ្រចិត្តនៅតាមសហគមន៍នៃអង្គការមិនមែនរដ្ឋាភិបាល។ក្នុងនោះ264នាក់មានប្រតិកម្មតេស្តវិជ្ជមាន ហើយបានបញ្ជូនទៅធ្វើតេស្តបញ្ជាក់ និងព្យាបាលនៅតាមគ្រឹះស្ថានសុខាភិបាលទូទាំង 66កន្លែងក្នុងប្រទេសកម្ពុជា។

បន្ថែមលើនេះលោកថាដោយឡែកលើការងារថែទាំ និងផ្តល់ការគាំទ្រផ្នែកផ្លូវចិត្តសម្រាប់អ្នកដែលរស់នៅជាមួយមេរោគអេដស៍ដែលមានតម្រូវការខ្ពស់ អង្គការសង្គមស៊ីវិល និងបណ្តាញនៃអ្នករស់នៅជាមួយមេរោគអេដស៍បានផ្តល់សេវាថែទាំនិងការគាំទ្រផ្លូវចិត្តសរុបចំនួន17,219នាក់ដែលក្នុងចំនួននេះ94% នៃពួកគេទទួលបានការគាំទ្រក្នុងការទទួលបានការព្យាបាលដោយថ្នាំប្រឆាំងនឹងមេរោគអេដស៍។

ចំណែកឯកឧត្តមអៀងមូលីទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានថ្លែងថា គិតមកត្រឹមឆ្នាំ 2016 នេះ អត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យដែលមានអាយុពី 15-49 ឆ្នាំ នៅកម្ពុជាគឺមាន0,6%ដែលបន្តធ្លាក់ចុះពី1.7%នៅក្នុងឆ្នាំ 1998 ហើយ 0.8% នៅក្នុងឆ្នាំ 2011 និង 0.7% នៅក្នុងឆ្នាំ 2012 ។ នេះមានន័យថា កម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបញ្ចប់ការរីករាលដាលមេរោគអេដស៍ប្រកបដោយជោគជ័យ និងប្រកបដោយក្តីសង្ឃឹម។

ឯកឧត្តមបន្តថា ចំពោះការថែទាំ និងព្យាបាលវិញ ក៏កម្ពុជាអាចសម្រេចក្នុងការផ្តល់ការព្យាបាលដោយ ឱសថប្រឆាំងមេរោគអេដស៍បានរហូតដល់ទៅជាង 80% ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ដែលត្រូវការឱសថប្រឆាំងមេរោគអេដស៍។ យើងមានសង្ឃឹមថា នឹងអាចឈានទៅសម្រេចបាន 90% នៅក្នុងឆ្នាំ 2020ខាងមុខនេះ។

បន្ថែមលើនេះ ឯកឧត្តមថា៖"ដោយឡែក មានអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ កុមារកំព្រា និងកុមារងាយរងគ្រោះដោយសារជំងឺអេដស៍ប្រមាណជា 70% ដែលតែងតែទទួលបាននូវការគាំទ្រសង្គម សេដ្ឋកិច្ច សុខភាពនិងអប់រំជាដើម"។

ក្នុងនោះដែរ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា ឥស្សរជនថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំតំបន់អាស៊ីប៉ាស៊ីហ្វិក ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា បានចេញសារលិខិត ដើម្បីចូលរួមក្នុងឱកាសទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ 1ធ្នូ ឆ្នាំ 2016 តាមទិសស្លោក **"ឆាប់ធ្វើតេស្តឈាម ឆាប់ព្យាបាល ឆ្ពោះទៅបញ្ចប់អេដស៍"**។

សារលិខិតនោះបានលើកឡើងថា រយៈពេល 25ឆ្នាំកន្លងមកនេះកម្ពុជាសម្រេចបាននូវសមិទ្ធផលប្រកបដោយមោទនភាព នៃយុទ្ធនាការរួមគ្នា ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បាននឹងកំពុងគ្រប់គ្រងស្ថានការណ៍ និងទប់ស្កាត់បានដោយជោគជ័យនូវការរីករាលដាលមេរោគអេដស៍ហើយបានបញ្ចៀសមនុស្សរាប់សែននាក់ឱ្យរួចផុតពីការឆ្លងមេរោគអេដស៍៕

# មជ្ឈមណ្ឌលសិក្សាពីចម្ងាយផ្សព្វផ្សាយនិង លើកកម្ពស់ការសិក្សាបែប E-learning


ឯកឧត្តម អ៊ុម រម្យណី


ឯកឧត្តម យក់ ង៉ុយ


លោក ហ៊ាន សំបឿន


ថ្នាក់ដឹកនាំសាកលវិទ្យាល័យ និងគណៈប្រតិភូរួមក្នុងវេទិកាផ្សព្វផ្សាយ និងលើកកម្ពស់ការសិក្សាតាមបែប E-Learning



មជ្ឈមណ្ឌលសិក្សាពីចម្ងាយ នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សហការជាមួយ ក្រសួងអប់រំ យុវជន និងកីឡា គ្រឹះស្ថានឧត្តមសិក្សានានា និងដៃគូជាតិ និងអន្តរជាតិ មកពីស្ថាប័នរដ្ឋ និងឯកជន បានរៀបចំវេទិកាពិភាក្សាមួយស្តីពីការសិក្សាពីចម្ងាយប្រចាំឆ្នាំ2016 (2016 e-learning forum) ជាលើកដំបូងឡើង ដើម្បីលើកកម្ពស់ការអប់រំ តាមការសិក្សាតាមបណ្តាញបច្ចេកវិទ្យា e-learning ក្នុងគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា។

ឯកឧត្តម យក់ ង៉ុយ រដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា បានថ្លែងថា ជាលទ្ធផលដែលកើតចេញពីការផ្តល់ការឧបត្ថម្ភ និងគាំទ្រពីភាគីកូរ៉េ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា បានរាយការណ៍ទៅកាន់ក្រសួងអប់រំយុវជននិងកីឡាពីលទ្ធផលនៃការអភិវឌ្ឍ សកម្មភាពរបស់ខ្លួនថាបានបង្កើតថ្នាក់រៀន និងគំរូនៃការការសិក្សាយ៉ាងឆ្លាតវៃ (flip classroom and blended learning) ដែលអភិវឌ្ឍវគ្គសិក្សាអនឡាញចំនួន 18 ក្រេឌីត ដើម្បីសិក្សា និងចែករំលែកទៅកាន់សាកលវិទ្យាល័យដៃគូរបស់ខ្លួនមួយចំនួនទៀត។

ឯកឧត្តម យក់ ង៉ុយ មានប្រសាសន៍ថា៖ "យើងទទួលស្គាល់ថាគំរូសិក្សាតាមបែប E-learning តាមរយៈការបង្កើត flip classroom and blended learning គឺមានសារសំខាន់ណាស់សម្រាប់សិស្សគ្រូបង្រៀនសាស្រ្តាចារ្យនិងការសិក្សាស្រាវជ្រាវដែលអាចចំណេញពេលវេលាច្រើន ហើយចំណុចលើសពីអ្វីដែលគ្រាន់តែជាការបង្រៀននៅក្នុងថ្នាក់"។

ឯកឧត្តម យក់ ង៉ុយ បានមានប្រសាសន៍ផងដែរថា ជាជំហានបន្ទាប់របស់យើង គឺយើងនឹងភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យទាំងអស់ឱ្យកាន់តែមានប្រសិទ្ធភាព និងមានភាពឆាប់រហ័សក្នុងការចែករំលែកធនធានចំណេះដឹង ដូចជា មុខវិជ្ជាលើ E-learning បណ្ណាល័យអេឡិចត្រូនិក (E-library) ឯកសារស្រាវជ្រាវ ការចែករំលែកតាមរយៈ Video Conference និង Steaming ជាដើម។

លោក ហ៊ាន សំបឿន ប្រធានមជ្ឈមណ្ឌលសិក្សាពីចម្ងាយនៃវិទ្យាស្ថានបច្ចេកវិទ្យាបានលើកឡើងថា មជ្ឈមណ្ឌលសិក្សាពីចម្ងាយត្រូវបានបង្កើតឡើងក្រោមគំនិតផ្តួចផ្តើមក្រោយកិច្ចប្រជុំអាស៊ានបូកជាមួយនឹងកូរ៉េនៅឆ្នាំ2009ដែលក្នុងនោះមានប្រទេសចំនួន4បានអនុវត្តន៍គឺកម្ពុជាឡាវមីយ៉ាន់ម៉ានិងវៀតណាម។ បន្ទាប់មកនៅឆ្នាំ 2012 ដោយមានការចង្អុលបង្ហាញរបស់ក្រសួងអប់រំយុវជននិងកីឡាកម្ពុជាក្រុមអ្នកជំនាញរបស់កម្ពុជាបានជ្រើសរើសយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ICT) ធ្វើជាទីតាំងមជ្ឈមណ្ឌលសិក្សាពីចម្ងាយ ដើម្បីផ្តល់ការអប់រំតាមរយៈការបង្កើតគំរូនៃមេរៀនតាមអនឡាញ និងថ្នាក់រៀនបែបឆ្លាតវៃដែលមានឈ្មោះថា FlipClassroom។

លោក ហ៊ាន សំបឿន បានមានប្រសាសន៍ថា៖ "ការសិក្សាតាមបែប E-learning គឺជាការសិក្សាដែលអាចឱ្យសិស្សរៀននៅគ្រប់ទីកន្លែងណាក៏ដោយឱ្យតែមានអ៊ីនធើណែត តាមរយៈមេរៀនដែលរចនាតាមបែបគរុកោសល្យច្បាស់លាស់និងមានដំណើរការបង្រៀនប្រកបដោយភាពច្នៃប្រឌិតខ្ពស់"។

លោក សំបឿន បានបន្ថែមទៀតថា ការសិក្សាតាមរយៈអនឡាញអាចធ្វើឱ្យនិស្សិតចំណេញពេលវេលាច្រើន ហើយមានលទ្ធភាពស្រាវជ្រាវជាអន្តរជាតិ។ ថ្មីៗនេះយើងបានចែករំលែកមេរៀនរបស់យើងទៅកាន់ប្រទេសផ្សេងៗទៀតដូចជាមីយ៉ាន់ម៉ា និងវៀតណាមជាដើម ហើយយើងបានលោតមកចំណាត់ថ្នាក់លេខ1 ដែលមានមេរៀនច្រើនជាងគេ។ រហូតមកដល់បច្ចុប្បន្ននេះយើងមានដៃគូសាកលវិទ្យាល័យមួយចំនួនដែលធ្វើការផ្លាស់ប្តូរមេរៀនតាមអនឡាញ និងផ្តល់ជំនួយផ្នែកបច្ចេកទេសក៏រួមទាំងសម្ភារ ដូចជាសាកលវិទ្យាល័យជាតិគ្រប់គ្រង សាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសាកលវិទ្យាល័យវិទ្យាសាស្រ្តសុខាភិបាល។

នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ឯកឧត្តម អ៊ុម រម្យណី បានបង្ហាញថា E-learning គឺជាកម្មវិធីយ៉ាងល្អមួយក្នុងការអភិវឌ្ឍវិស័យអប់រំ។ យើងអាចបង្រួមវគ្គសិក្សាដែលសាំញ៉ាំក្លាយជាវគ្គដែលងាយស្រួលរៀន និងមានវិសាលភាពធំទូលាយតាមរយៈបណ្តាញអនឡាញដែលមានគ្រប់ទីកន្លែងលើពិភពលោក។ វគ្គសិក្សាតាមបែប E-learning នេះបានជំរុញឱ្យសិស្សកាន់តែមានលទ្ធភាពច្រើនដើម្បីសិក្សាស្រាវជ្រាវ និងថែមទាំងអាចសិក្សាពីបណ្តាប្រទេសផ្សេងៗតាមរយៈគណនីរបស់គេម្នាក់ៗ ដែលមជ្ឈមណ្ឌលសិក្សាពីចម្ងាយប្រគល់ជូនជាមួយនឹងលេខកូដសម្ងាត់ផ្ទាល់ខ្លួន"។

ឯកឧត្តម អ៊ុម រម្យណី បានមានប្រសាសន៍ថា៖ "មជ្ឈមណ្ឌលសិក្សាពីចម្ងាយមិនត្រឹមតែផ្តល់ជូនការអប់រំតាមបែបឆ្លាតវៃ និងប្រកបដោយប្រសិទ្ធភាពប៉ុណ្ណោះទេ តែយើងក៏ផ្តល់ជូនផងដែរសម្រាប់សាកលវិទ្យាល័យដៃគូដែលបានចុះអនុស្សារណៈព្រមព្រៀងគ្នានូវផលប្រយោជន៍ជាច្រើនសម្រាប់អភិវឌ្ឍសមត្ថភាពសិស្សរបស់ខ្លួន។ យើងផ្តល់ជូនជំនួយបច្ចេកទេស និងថែមទាំងផ្តល់ជូនសម្ភារបរិក្ខាមួយចំនួន ដូចជាការអនុញ្ញាតឱ្យប្រើប្រាស់បន្ទប់ផ្សាយ (Studio) នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាដើម្បីផលិតមេរៀនជាដើម"។

ឯកឧត្តម អ៊ុម រម្យណី បានបន្ថែមទៀតថា នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា គឺមានការលើកទឹកចិត្តដល់សាស្រ្តាចារ្យដែលបានចូលរួមចំណែកផលិតមេរៀនតាមបែបE-learningតាមរយៈការផ្តល់ប្រាក់ម៉ោងពេញសម្រាប់ពួកគាត់ បើទោះបីជាគាត់មិនបានមកបង្រៀនដោយផ្ទាល់ក៏ដោយ។

គួរបញ្ជាក់ថា ការបង្កើតវេទិកាពិភាក្សាអំពីការសិក្សាពីចម្ងាយប្រចាំឆ្នាំ2016នេះគឺដើម្បីកសាងយន្តការកិច្ចសហប្រតិបត្តិការ និងបង្កើតកិច្ចសន្ទនារវាងក្រសួងអប់រំយុវជន និងកីឡា និងគ្រឹះស្ថានសិក្សានានាជាមួយនឹងស្ថាប័នពាក់ព័ន្ធទាំងរដ្ឋ និងឯកជន ដើម្បីធ្វើការរួមគ្នាក្នុងការបង្កើតបរិយាកាសសិក្សាដែលល្អជាងមុនសម្រាប់សិក្សាតាមអនឡាញនៅកម្ពុជា។ លើសពីនេះទៅទៀតវេទិកានេះក៏ត្រូវធ្វើឡើងដើម្បីផ្តល់ឱកាសក្នុងការលើកយកបញ្ហាទាក់ទិននឹងការប្រើប្រាស់គំរូនៃការសិក្សា E-learning មកពិភាក្សាដើម្បីស្វែងរកដំណោះស្រាយពីសំណាក់គ្រឹះស្ថានសិក្សា និងអ្នកជំនាញពីក្រុមហ៊ុនទូរគមនាគមន៍ធំៗនៅកម្ពុជា៕

# រថយន្ត Ford ចំនួនជាង 80 គ្រឿងត្រៀមដំណើរកម្សាន្តបោះជំរំទៅទឹកដីថៃ

ដើម្បីលើកទឹកចិត្តដល់អតិថិជនខ្លួនក្រុមហ៊ុន Ford បានរៀបចំកម្មវិធីដំណើរកម្សាន្តបោះជំរំលើកទី10ឆ្ពោះទៅកាន់ខេត្តឧត្តរមានជ័យប្រទេសកម្ពុជា និងខេត្តបុរីរាម ប្រទេសថៃ ដែលមានរយៈពេល 4 ថ្ងៃ ដែលមានរថយន្តចូលរួមក្បួនជាង 80 គ្រឿង ដោយមានអ្នកដំណើរប្រមាណ 400 នាក់។

ដំណើរកម្សាន្តនោះនឹងធ្វើឡើងចាប់ពីថ្ងៃទី 8 ដល់ថ្ងៃទី 11 ខែធ្នូ ឆ្នាំ2016 ដែលអ្នកចូលរួមនឹងរីករាយ ជាមួយទេសភាព ព្រៃភ្នំនៅតាមដងផ្លូវ ក្នុងទឹកដីខេត្តឧត្តរមានជ័យ រួមជាមួយនឹងបទពិសោធន៍បោះជំរំដ៏អស្ចារ្យនៅលើវាលស្មៅយ៉ាងស្រស់ត្រកាលនៃខេត្តបុរីរាម ប្រទេសថៃ។ លើសពីនេះទៅទៀត អ្នកចូលរួមទាំងអស់នឹងមានឱកាសដើរទិញទំនិញជាច្រើនសម្បូរបែបក្នុងតម្លៃសមរម្យក្នុងផ្សារទំនើបនៃទឹកដីខេត្តបុរីរាម ប្រទេសថៃថែមទៀតផង។

លោក សេង រឹង នាយកគ្រប់គ្រងផ្នែករថយន្ត Ford បានឱ្យដឹងថា ដំណើរកម្សាន្តឆ្នាំនេះ នឹងកាន់តែធ្វើឱ្យអ្នកចូលរួមនឹងរីករាយ កាន់តែខ្លាំងជាងឆ្នាំមុនៗថែមទៀត។ ដំណើរកម្សាន្ត FORD Adventure មិនត្រឹមតែជាការកម្សាន្តសប្បាយប៉ុណ្ណោះទេ អ្វីដែលសំខាន់ជាងនេះទៅទៀតនោះ គឺការទំនាក់ទំនងគ្នាល្អការជួយគ្នាទៅវិញទៅមករបស់អតិថិជន FORD និងបុគ្គលិករបស់ក្រុមហ៊ុន អរិមអេខេមបូឌា។

លោកថ្លែងថា៖“ដំណើរកម្សាន្តលើកនេះ ខ្ញុំគិតថាវានឹងមានភាពអស្ចារ្យជាងឆ្នាំមុនៗ ជាមួយនឹងក្បួនរថយន្ត Ford ជាង 80 គ្រឿង ដែលវានឹងធ្វើឱ្យអតិថិជនយើងទទួលបានបទពិសោធន៍ក្នុងការបើកបរ និងទស្សនាតំបន់ទេសចរណ៍នៅទឹកដីប្រទេសថៃផងដែរ”។

សម្រាប់ដំណើរកម្សាន្តនេះ បានធ្វើឡើងជារៀងរាល់ឆ្នាំ ដោយឆ្នាំ2007 ក្រុមហ៊ុនធ្វើដំណើរទៅខេត្តមណ្ឌលគិរី ឆ្នាំ2008 ទៅកាន់ខេត្តរតនគិរី ឆ្នាំ2009 ទៅកាន់ខេត្តប៉ៃលិន ឆ្នាំ2010 និងឆ្នាំ2011 ទៅកាន់ទឹកដីខេត្តចម្ប៉ាសាក់ ប្រទេសឡាវ ឆ្នាំ 2012 ទៅកាន់ខេត្តមណ្ឌលគិរី ឆ្នាំ2013 បានទៅទឹកដីប្រទេសឡាវម្តងទៀតហើយឆ្នាំ2014 ទៅកាន់ខេត្តត្រាត ប្រទេសថៃ និងឆ្នាំ 2015 ទៅកាន់ខេត្តច័ន្ទបុរី ប្រទេសថៃ ជាមួយនឹងកំណើនអ្នកចូលរួមកាន់តែកើនឡើងជាបន្តបន្ទាប់៕









cjcc Business

## Total Quality Management

TQM means that every employees' efforts can lead to the company's profits UP. Not only it makes company's profits UP, but also it leads employees' motivation UP.



**Mr. Shibata Masato: Chief Researcher of Global Development &. Management Consultants Inc.** He has been a specialist in Quality and Production control for over 25 years in AISIN SEIKI Co. Ltd *(Automobile Parts Production Maker, one of the TOYOTA group companies)*. He also had joined JICA Senior Volunteer Activity as a business consultant.

### Course Information:

- **Topic**: Total Quality Management (TQM)
- **Date**: Thursday-Friday, 15-16 December ,2016
- **Time**: 8:30-17:00
- **Venue**: CJCC/Room 5
- **Language Use**: English
- **Fee**: $100
- **Registration**: fill in application form and send to btd@cjcc.edu.kh.
- **Note**: Refreshment will be served. Certificate is provided for participants who have at least 70% attendance.
- **Contact Number**: 099 918 191/ 098 333 033

### Who should attend the course?

Those who are entrepreneurs in manufacturing companies or company'staff involving quality and productivity improvement.

### Course Contents:

- Why is TQM needed?
- TQM Activity procedure
- Decide the target and deadline
- Allocate the task to each department
- TQM Implementation In each dep
- Personal Tools =TQM Idea's Suggestion Box
- Group Tools =QC circle competition
- Make sure of TQM results

### Why is TQM needed?

- It makes employee's work more smooth, speedy and efficient.
- It leads motivation up for all employees



Total Quality Management

CAMBODIA - JAPAN COOPERATION CENTER
Russian Confederation Blvd, Tuol Kork, Phnom Penh, CAMBODIA
Tel: (+855) 23 883 649 / 077 801 005 / 023 880 514
Email: btd@cjcc.edu.kh Website: www.cjcc.edu.kh

SOCIAL MEDIA : go.cjcc.edu.kh
Facebook / Google + / Youtube / Twitter / Linkedin

CAMBRIDGE Child Development Centre

A Premier Pre-School from Singapore

Accepting children aged 2 months to 6 years !

Open from 7:00AM - 6:00PM




- English, Khmer and Mandarin Literacy
- Swimming, music, and much more
- Science Discovery
- Fun Cookery

Contact Us: 023 229 333
www.cambridgecdc.net

# Nokia នឹងចូលទីផ្សារវិញខណៈ Microsoft ត្រៀមផលិត...

តពីទំព័រ(01)... យក្សអាមេរិកមួយនេះ ក៏នឹងត្រៀមបញ្ចេញស្មាតហ្វូនកូនកាត់ថេបប្លេតមានឈ្មោះថា Surface Phone នឹងគេដែរ។

ប្រកាសសេចក្តីលម្អិតនៃស្មាតហ្វូនថ្មីរបស់ខ្លួននៅសមាជទូរស័ព្ទពិភពលោកឆ្នាំ 2017។ សមាជិកទូរស័ព្ទពិភពលោកឆ្នាំ2017 នឹងត្រូវប្រារព្ធធ្វើឡើងនៅថ្ងៃទី27ខែកុម្ភៈនិងថ្ងៃទី2ខែមីនាក្នុងទីក្រុង Barcelona ប្រទេសអាឡឺម៉ង់។ ការវិវត្តនៃទូរស័ព្ទស៊េរីថ្មី ក្រុមហ៊ុន Nokia ដើរតួត្រឹមជាអ្នកត្រួតពិនិត្យលើគុណភាព និងភាពត្រឹមត្រូវនៃផលិតផលប៉ុណ្ណោះ ដោយការផលិតទាំងអស់ជាបន្ទុករបស់ក្រុមហ៊ុន HMD Global និងមានការចូលរួមពីក្រុមអ្នកស្រាវជ្រាវ អ្នកអភិវឌ្ឍ និងអ្នកជំនាញក្នុងការផលិតរបស់ក្រុមហ៊ុន Foxconn ។

ជាមួយគ្នានោះ ក្រុមហ៊ុន HMD Global គ្រោងនឹងចំណាយយ៉ាងហោចណាស់ 500 លានដោនស្មើនឹង 721 លានសហភាពអាហ្វ្រិក (AU$721 millions) នៅលើទីផ្សារ និងការផ្សព្វផ្សាយរបស់ក្រុមហ៊ុន Nokia នៅក្នុងបរិបទស្មាតហ្វូនរយៈពេល 3 ឆ្នាំដំបូង។ ជាមួយនឹងវិធីសាស្រ្តនេះ ម៉ាក Nokia នឹងធ្វើឱ្យរលកឧស្សាហកម្មប្រភេទនេះ មានការប្រកួតប្រជែងខ្លាំងនៅលើទីផ្សារសកល។

ជាមួយនឹងការប្រកាសចូលទីផ្សាររបស់ Nokia ព័ត៌មានស្តីពីការត្រៀមខ្លួនបង្កើតស្មាតហ្វូន ប្រើឈ្មោះផ្ទាល់ខ្លួនរបស់ក្រុមហ៊ុន Microsoft ក៏បានលេចមកជាថ្មីម្តងទៀត ក្រោយគ្រោងការមួយនេះ បានបង្ហើបឱ្យដឹងកាលពីប៉ុន្មានឆ្នាំមុន។ តាមរបាយការណ៍ពីគេហទំព័រ Commercial Times បានឱ្យដឹងថា ក្រុមហ៊ុនមួយ ដែលត្រូវបានគេស្គាល់ថាជាក្រុមហ៊ុនផ្នែកផ្គត់ផ្គង់ដ៏ធំរបស់ក្រុមហ៊ុន Apple បាននឹង កំពុងតែធ្វើការងារជាមួយនឹងក្រុមហ៊ុន Microsoft ក្នុងការចាប់ផ្តើមធ្វើផលិតកម្មនូវទូរស័ព្ទប្រភេទ Microsoft Surface Phone ដែលអ្នកទាំងអស់គ្នាបានរង់ចាំមើលអស់រយពេលជាយូរមកហើយ។







ប្រភពព័ត៌មានឱ្យដឹងថាទៀតថា Surface Phone របស់ Microsoft នឹងធ្វើការបង្ហាញខ្លួនជាផ្លូវការនៅឆ្នាំ2017 ខាងមុខនេះ ដោយមានអេក្រង់ទំហំ 5.5 អ៊ីញ ប្រភេទ 2K Quad HD ហើយបំពាក់ CPU ប្រភេទ Qualcomm Snapdragon 835 និងមានជម្រើស 2 សម្រាប់ជ្រើសរើសគឺ RAM ទំហំ 6 GB និង RAM ទំហំ 4 GB។ មិនតែប៉ុណ្ណោះ SurfacePhone នឹងដំណើរការដោយ Windows10 Mobile ដែលបានបំពាក់បច្ចេកវិទ្យា Continuum ដើម្បីឱ្យទូរស័ព្ទដំណើរការបានដូចជាកុំព្យូទ័រ PC ផងដែរ។ ព័ត៌មាននេះត្រូវបានលេចឮ បន្ទាប់ពី 2 ឬ 3 ថ្ងៃ ក្រោយពីនាយកប្រតិបត្តិរបស់ក្រុមហ៊ុន Microsoft បាននិយាយអំពីអនាគតរបស់ក្រុមហ៊ុននៅក្នុងព្រឹត្តិការណ៍អាជីវកម្មទូរស័ព្ទ និងថាខ្លួននឹងខិតខំដើម្បីឈានទៅដល់ការទទួលបានជោគជ័យ ដោយធ្វើឱ្យបាន"ឧបករណ៍ចល័តចុងក្រោយដែលល្អបំផុត"និងបាននិយាយថាក្រុមហ៊ុននឹងមិនបោះបង់ការផលិតនូវទូរស័ព្ទស្មាតហ្វូននោះឡើយ៕

# JAGUAR F-PACE បង្ហាញខ្លួនប្រជែងទីផ្សាររថយន្តប្រភេទ SUV នៅកម្ពុជា




ក្រុមហ៊ុន Jaguar Range Rover ប្រចាំប្រទេសកម្ពុជា បានធ្វើការសម្ពោធលក់ជាផ្លូវហើយនូវរថយន្ត Jaguar ម៉ូឌែល F-Pace ដែលជារថយន្តប្រភេទ SUV ដ៏ទំនើបដំបូងបំផុតរបស់ខ្លួនក្នុងទីផ្សារកម្ពុជា ក្រោយចេញសេចក្តីប្រកាសស្តីពីការនាំចូលប្រភេទរថយន្តនេះ កាលពី 4 ខែមុន។

លោក Paul Varley អ្នកគ្រប់គ្រងទូទៅរបស់ Jaguar Land Rover បានឱ្យដឹងថា F-Pace ជាប្រភេទរថយន្តប្រណីត SUV ដំបូងគេបង្អស់របស់ Jaguar ដែលត្រូវបានរចនាឡើងជាលក្ខណៈបែបរថយន្តស្ព័រដើម្បីវាយលុកទីផ្សាររថយន្តប្រភេទ SUV នៅកម្ពុជា ខណៈរថយន្តនេះត្រូវបានបំពាក់នូវបច្ចេកវិទ្យាទំនើបចុងក្រោយ និងលក្ខណៈពិសេសជាច្រើន ដែលរថយន្តប្រភេទ SUV ផ្សេងទៀតមិនមាន។ លក្ខណៈ ទាំងនេះ ធ្វើឱ្យ F-Pace មានភាពលេចធ្លោ ផ្តល់នូវសុវត្ថិភាពខ្ពស់ ផាសុកភាព និងឧត្តមភាព ដែលសមរម្យសម្រាប់គ្រួសារដ៏ថ្លៃថ្នូរ និងស៊ីវិល័យ។ លោកបន្តថា រថយន្តបែបស្ព័រដ៏ទំនើបនេះ ត្រូវបានផលិតពីដែកអាលុយមីញ៉ូម (Aluminum) ដែលធ្វើឱ្យរថយន្តមានភាពមាំស្វិតស៊ីប្រេងតិច និងមានសន្ទុះខ្លាំង។

អ្នកគ្រប់គ្រងរូបនេះថ្លែងថា៖" ជាលើកទីមួយដែលយើងផលិតរថយន្តប្រភេទនេះ។ F-Pace ត្រូវបានរចនាជាលក្ខណៈបែបរថយន្តស្ព័រដែលអ្នកបើកបរមានអារម្មណ៍ហាក់ដូចជាមិនកំពុងបើកបររថយន្តប្រភេទ SUV។ ខ្ញុំជឿជាក់ថា អ្នកបើកបរច្បាស់ជាពេញចិត្តក្រោយបានបើកសាកល្បងរថយន្តនេះ"។

លោកបន្តទៀតថា ទោះបីជា Jaguar F-Pace ជារថយន្តប្រភេទ SUV លើកដំបូងរបស់ក្រុមហ៊ុន ប៉ុន្តែវាត្រូវបានបំពាក់នូវបច្ចេកវិទ្យាទំនើបៗនៃរថយន្តស្ព័រ ដែលវាអាចឆ្លើយតបទៅនឹងស្ថានការណ៍ផ្សេងៗបានយ៉ាងឆាប់រហ័ស និងសំឡេងស្ងាត់មានស្ទុះ និងកម្លាំងខ្លាំង ដែលវាសក្តិសមបំផុតសម្រាប់ស្ថានភាពផ្លូវកោងខ្លាំងផ្លូវភក់ផ្លូវទួលថ្មនិងតូចចង្អៀត។ រថយន្តនេះ មានកម្លាំងសន្ទុះខ្លាំងដូចរថយន្តប្រណាំង ដែលអាចបង្កើនល្បឿនពី 0 ដល់ 100 គីឡូម៉ែត្រក្នុង1ម៉ោងក្នុងរយៈពេលត្រឹមតែ 5.5 វិនាទី ហើយមានប្រព័ន្ធប្រព័ន្ធគ្រឿងក្រោម មានបំពាក់បូម និងម៉ូស័រភ្លោះ ដែលជាជំនួយទប់លំនឹងក្នុងពេលបើកបរលើផ្លូវកោង ឬជង្ហុក។

ដោយឡែកផ្នែកខាងក្នុងនៃរថយន្ត វាមានអេក្រង់ 12.3 អ៊ីញ និងមានមុខងារទំនើបដែលអាចប្រើសម្រាប់ទូរស័ព្ទហៅចេញ/ចូល ប្រព័ន្ធចែករំលែក WiFi(Personal Hotspot) ទទួល និងអានអ៊ីម៉ែល ប្រើប្រាស់បណ្តាញសង្គម Facebook Youtube លើអេក្រង់បានដោយងាយស្រួល។ អ្នកបើកបរក៏អាចផ្លាស់ប្តូរកៅអីអង្គុយឱ្យខ្ពស់ឬទាបបញ្ឈរឬផ្តេកតាមតម្រូវការដោយបញ្ជាលើអេក្រង់បានផងដែរ។

អ្វីដែលកាន់តែទំនើប និងជាបច្ចេកវិទ្យាលើកដំបូងគេ គឺ Smart Key ដែលយើងអាចពាក់ជាប់នឹងកដៃ មិនជ្រាបទឹក អាចប្រើជំនួសកូនសោរបាន។ SmartKey នេះផ្តល់ភាពងាយស្រួលសម្រាប់អ្នកស៊ីវិល័យ និងធុញទ្រាន់នឹងការកាន់កូនសោរច្រើន។ ផ្នែកខាងក្នុងមានទំហំធំទូលាយ មានកៅអីចំនួន 5 ដែលផ្តល់នូវផាសុកភាពដល់អ្នកបើកបរ និងអ្នករួមដំណើរជាមួយ។ ស្រោមពូកត្រូវរចនាជាលក្ខណៈរថយន្តស្ព័រដ៏ស្រស់ស្អាត ដែលអាចរើសពណ៌ច្រើនជម្រើសទៅតាមចំណង់ចំណូលចិត្តរបស់អតិថិជន។

រថយន្ត Jaguar F-Pace ក៏មានបំពាក់ប្រព័ន្ធការពារសុវត្ថិភាពបន្ថែមជាច្រើនទៀតមានដូចជា៖ ប្រព័ន្ធគ្រប់គ្រងគន្លងផ្លូវ ប្រព័ន្ធជំនួយពេលចូលចត ឬជំនួយពេលបើកបរ ប្រព័ន្ធកំណត់សម្គាល់សញ្ញាចរាចរណ៍ ឬរថយន្តផ្សេងពេលដែលអ្នកបើកបរមើលមិនឃើញ ប្រព័ន្ធកំណត់ល្បឿនស្វ័យប្រវត្តិ កាមេរ៉ា 360 ដឺក្រេ ប្រព័ន្ធគ្រប់គ្រងលំនឹងឌីណាមិចជាដើម ដែលរឹតតែធ្វើឱ្យអ្នកបើកបរមានទំនុកចិត្តខ្ពស់ ពេលដែលកំពុងបើកបរ៕

# Huawei ក្លាយជាក្រុមហ៊ុនផលិតស្មាតហ្វូនប្រើប្រព័ន្ធ Android ដែលទទួលបានប្រាក់ចំណេញខ្ពស់ជាងគេ

ក្រុមហ៊ុនបច្ចេកវិទ្យារបស់ចិន Huawei បានក្លាយជាក្រុមហ៊ុនផលិតស្មាតហ្វូនប្រើប្រាស់ប្រព័ន្ធ Android ដែលទទួលបានប្រាក់ចំណេញខ្ពស់ជាងគេក្នុងពិភពលោក គិតត្រឹមត្រីមាសទី 3 ឆ្នាំ2016 នេះ។ របាយការណ៍នេះ ត្រូវបានបង្ហាញពីក្រុមហ៊ុនផ្ដល់ប្រឹក្សា និងស្រាវជ្រាវផ្នែកទីផ្សារ Strategy Analyticsនៅរដ្ឋ Massachusetts នៃសហរដ្ឋ-អាមេរិកកាលពីពេលថ្មីៗនេះ។



លោក Neil Msawston នាយកប្រតិបត្តិក្រុម-ហ៊ុនStrategyAnalytic បានឱ្យដឹងថាក្រុមហ៊ុនលោកបានធ្វើការព្យាករណ៍ឃើញថា ក្រុមហ៊ុន Huawei បានប្រាក់ចំណេញពីប្រតិបត្តិការលក់ស្មាតហ្វូនទូទាំងសកលលោកបានចំនួន0.2ពាន់លានដុល្លារអាមេរិកក្នុងត្រីមាសទី3ឆ្នាំ2016នេះ។លោកបន្ថែមថាក្រុមហ៊ុនបច្ចេកវិទ្យាយក្សរបស់ចិនមួយនេះបានច្បាមយកចំណែក 2.4% នៃប្រាក់ចំណេញលើអាជីវកម្ម ស្មាតហ្វូនទាំងអស់ ហើយកំពុងឈរនៅលំដាប់ថ្នាក់ទី 2 លើប្រាក់ចំណេញក្នុងអាជីវកម្មស្មាតហ្វូនសរុបរួមបន្ទាប់ពី Apple កំពុងក្លាយខ្លួនជាក្រុមហ៊ុនលក់ទូរស័ព្ទដៃប្រភេទ Android ដែលទទួលប្រាក់ចំណេញច្រើនជាងគេបង្អស់ក្នុងពិភពលោក ជាលើកដំបូងបង្អស់របស់ខ្លួន។

ជាមួយគ្នានោះដែរ លោក Lujuain នាយកគ្រប់គ្រង Huawei Mobile Device ប្រចាំប្រទេសកម្ពុជា បានឆ្លើយតបនឹងភាពជោគជ័យដ៏ធំរបស់ក្រុមហ៊ុននេះថា ក្រុមហ៊ុន Huawei តែងឱ្យតម្លៃទៅលើសន្តិសុខសុវត្ថិភាព និងឯកជនភាពរបស់អតិថិជន ដូច្នេះក្រុមហ៊ុនតែងតែព្យាយាមខិតខំការពារនូវសន្តិសុខសុវត្ថិភាព និងឯកជនភាពរបស់ពួកគេជាចម្បង។

លោកថា៖“ខ្ញុំជឿជាក់ថានេះគឺជាកត្តាមួយដែលជំរុញឱ្យក្រុមហ៊ុន របស់យើងទទួលបានជោគជ័យ។ គេគ្មានមន្ទិលសង្ស័យទ្បើយដែលក្រុមហ៊ុនមួយនេះ អាចដណ្តើមបានចំណាត់ថ្នាក់កំពូលដូច្នេះ”។

ភាពជោគជ័យនេះ ត្រូវបាននាយកប្រតិបត្តិក្រុមហ៊ុន Strategy Analytic បញ្ជាក់ថា ក្រុមហ៊ុន Huawei បានទទួលឱកាសល្អ ក្រោយក្រុមហ៊ុន Samsung ជួបនូវឧប្បត្តិហេតុទូរស័ព្ទ Samsung Galaxy Note 7 មានបញ្ហាផ្ទុះឆេះ ដែលនាំឱ្យក្រុមហ៊ុននេះខាតបង់ប្រាក់ចំណេញយ៉ាងហោចណាស់ 5.3 ពាន់លានដុល្លារ។

កត្តាមួយទៀតមកពីចំនួនការលក់របស់Huawei នៅតំបន់អាមេរិកឡាទីន កើនឡើងខ្ពស់រហូតដល់ទៅ 10 លានគ្រឿង។ ទិន្នន័យនៃការលក់នេះ ត្រូវបានទម្លាយដោយលោក Yu Cheng dong អនុ-ប្រធានជាន់ខ្ពស់របស់ក្រុមហ៊ុន Huawei ពេលបង្ហោះចែករំលែកនូវរូបភាពរបស់កីឡាករបាល់ទាត់ដ៏ល្បីឈ្មោះទូទាំងពិភពលោក Lionel Messi ។ ក្រុមហ៊ុនបច្ចេកវិទ្យារបស់ប្រទេសចិននេះ ក៏មានគម្រោងក្នុងការពង្រីកវត្តមានរបស់ខ្លួនទៅកាន់អាមេ-រិកខាងត្បូង ហើយភស្តុតាងដែលបង្ហាញកាន់តែច្បាស់នោះ គឺថាក្រុមហ៊ុននេះ បានធ្វើការប្រកាសរួចមកហើយថាក្រុមហ៊ុននឹងបើកហាងលក់រាយដល់ទៅ 1,500 ហាងនៅក្នុងតំបន់នៅឆ្នាំនេះ៕



# ដំណឹងអាហារូបករណ៍សម្រាប់ សិស្ស-និស្សិត

## ឱកាសផ្លាស់ប្តូរកម្មសិក្សាទៅសហគមន៍អឺរ៉ុប

Project ALFABET គឺជាកម្មវិធីផ្លាស់ប្តូរកម្មសិក្សាមួយក្នុងចំណោមកម្មវិធីជាច្រើនដែលគាំទ្រដោយកម្មវិធីអាហារូបករណ៍ Erasmus Mundus ។ កម្មវិធីមួយនេះនឹងផ្តល់ឱកាសដល់និស្សិតគ្រប់កម្រិតថ្នាក់ឧត្តមសិក្សានៅតាមបណ្តាប្រទេសនៃតំបន់អាស៊ីទៅធ្វើការផ្លាស់ប្តូរកម្មសិក្សារយៈពេលខ្លីនៅសាកលវិទ្យាល័យមួយក្នុងសហគមន៍អឺរ៉ុប។

**ជំនាញសិក្សា៖**

Agriculture, Food Safety and Security, Technologies in Life Sciences, Balanced Managementof the Natural Resources, Sustainable Rural Development, Adaptation to Climate Change,etc...

**លក្ខខណ្ឌជ្រើសរើស៖**

- មានសញ្ជាតិខ្មែរ
- ជានិស្សិត ឬអតីតនិស្សិតនៃសាកលវិទ្យាល័យមួយក្នុងប្រទេសកម្ពុជា
- មានសញ្ញាបត្រគ្រប់គ្រាន់និងសមស្របតាមកម្រិតថ្នាក់ដែលចង់សិក្សា
- មានចំណេះដឹងភាសាសមស្របតាមភាសាដែលប្រើប្រាស់តាមសាកលវិទ្យាល័យដែលជ្រើសរើស

**ឯកសារចាំបាច់មួយចំនួន៖**

- Application form ( see below for online application )
- CV ( Europass Format ) more information
- Evidence of Academic Achievements / Transcript of records
- Language proficiency
- Motivation Letter
- Recommendation letter ( just 1 letter is needed ! )
- Passport copy
- Research Proposal ( PhD and Post doc candidates only )

ការដាក់ពាក្យ៖ បេក្ខជនត្រូវដាក់ពាក្យតាមរយៈ Online Application Form

កាលបរិច្ឆេទផុតកំណត់៖ ០៦ មករា ២០១៧

## អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រទៅ University of Tsukuba ជប៉ុន

The University of Tsukuba, Japan is offering scholarship to undergraduate students admitted in English program in the university.

Undergraduates programs use a two-stage screening method.

- The first stage is a paper based screening, where applicants are required to submit their application, academic transcript, academic recommendation letter, personal statement, and financial plan.
- The second stage is a brief interview via teleconferencing. The interview will comprise a mix of general and subject specific questions.

2017 Application Guidelines

- Online Registration and Payment of the Examination Fee for the First Stage Screening: November 15, 2016 to December 26, 2016
- Please click here to start the online registration and print out Entry Form ( Form 1 ). Before starting the registration, please prepare a photo of yourself to upload for identification. The ID photo must be taken within the last three months with no hats or other adornments. Please take the photo with your glasses on if you will be wearing glasses during interviews. Please note, no confirmation email will be sent.
- Payment website link - https://e-shiharai.net/english/
- Acceptance of Application Documents: Must be received by January 10, 2017
- Notification of Examinee Number: January 23, 2017
- Announcement of Successful Applicants from the First Stage Screening: February 8, 2017
- Payment of the Examination Fee for the Second Stage Screening: February 9, 2017 to February 23, 2017
- Second Stage Screening ( Individual Interviews ): February 27, 2017 to March 10, 2017
- Announcement of Final Successful Applicants: March 23, 2017
- Enrollment Procedures: April 7, 2017 to April 20, 2017
- Enrollment Date: September 1, 2017
- Entrance Ceremony and Orientation: Late September 2017

## Call for Applications to Australian Award Scholarship Intake 2018 from Cambodians

Deadline: February 1 – April 30, 2017

Location: Australia

Type: Scholarship, Master and PhD

Program Period: Varies

Number of Awards: Not specified

Course Starts: Intake 2018

Australia Awards Scholarships (AAS) are open to applicants from the Royal Government of Cambodia, public sector agencies, non-government organisations, civil society organisations and the private sector.

**Study Areas**

Applications are open from all fields of study except general management degrees, such as a Master of Business Administration, but applicants should select courses that align with their experiences and qualifications.

**Level of Study**

Australia Awards Scholarships are long-term awards providing Cambodians with the opportunity to obtain postgraduate qualifications at a Masters level (by coursework only) and in exceptional cases PhD level at an Australian tertiary institution.

**Scholarship**

- Return air travel
- A one-off establishment allowance on arrival
- Full tuition fees
- Contribution to living expenses
- Introductory academic program
- Overseas Student Health Cover for the duration of the Scholarship
- Supplementary academic support
- Fieldwork allowance (for research students only).

**Eligibility**

- Be a citizen of Cambodia (only).
- Be a resident of Cambodia for a period of 24 months immediately prior to 1 February 2017 (i.e. the day applications open) other than for short absences related to employment, professional development or holidays.
- Already hold a Bachelor degree, if applying for a Masters; or already hold a Masters, if applying for a PhD.
- Have enough English Proficiency; For Masters IELTS score of 5.5 overall with no sub-band less than 5.0 (or TOEFL equivalent). For PhD IELTS score of 6.5 overall with no sub-band less than 6.0 (or TOEFL equivalent)
- Have at least 24 months full-time (equivalent) work experience.

In the case of applicants applying for a Masters scholarship, preference will be given to applicants who do not already have a Masters degree from another country (other than Cambodia).

**How to Apply**

Online applications

Apply online at: https://oasis.dfat.gov.au

When applying online, all supporting documents must be uploaded to meet the specific eligibility requirements for Cambodia.

Hardcopy applications

Application forms can be downloaded at:www.australiaawardscambodia.org.

Hardcopy applications can be collected from these Australian Centre for Education (ACE) campuses.

LA REINE MEDIA

# ដំណឹងជ្រើសរើសបុគ្គលិក

ក្រុមហ៊ុន **ឡារ៉ែន មេឌៀ** (**ទស្សនាវដ្ដី ឡារ៉ែន** និង **កាសែត ឡារ៉ែនពាណិជ្ជ**) ត្រូវការជ្រើសរើសបុគ្គលិកផ្នែកលក់ពាណិជ្ជកម្ម (**Senior Sales**) ទាំងពីរភេទ ចំនួន 2នាក់ ដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម:

- ចប់បាក់ឌុប (ឬបញ្ចប់បរិញ្ញាបត្រខាងផ្នែកគ្រប់គ្រង ឬផ្នែកទីផ្សារ កាន់តែប្រសើរ)
- ត្រូវមានបទពិសោធន៍លើការងារផ្នែកលក់ពាណិជ្ជកម្មកាសែត និងទស្សនាវដ្ដី 1ឆ្នាំឡើងទៅ
- អាចចេះសរសេរ និងនិយាយភាសាអង់គ្លេសបាន
- ត្រូវមានភាពប៉ិនប្រសព្វ រួសរាយរាក់ទាក់ក្នុងការទំនាក់ទំនងភ្ញៀវ
- ត្រូវមានភាពរហ័សរហួន ម្ចាស់ការ និងចេះទទួលខុសត្រូវលើការងាររបស់ខ្លួន
- ត្រូវមានភាពស្មោះត្រង់ អត់ធ្មត់នឹងការងារ
- ត្រូវមានមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន

ក្រុមហ៊ុនផ្ដល់ជូនប្រាក់ខែខ្ពស់សមរម្យ និងមានភាគរយ (Commission 5%-10%) បន្ថែមទៀត។

បេក្ខជន ឬ បេក្ខនារីដែលមានចំណាប់អារម្មណ៍ សូមទាក់ទងតាម អាសយដ្ឋាន អគារលេខ 57 មហាវិថីព្រះសីហនុ សង្កាត់ចតុមុខ ខណ្ឌដូនពេញ
លេខទូរស័ព្ទ: 081 678 111
**Email: info@lareine.com.kh**
**Cc: naren@lareine.com.kh**

*ឈប់ទទួលពាក្យ: ថ្ងៃទី 15 ខែ ធ្នូ ឆ្នាំ2016

ឡារ៉ែន LAREINE MAGAZINE | កាសែត ឡារ៉ែន ពាណិជ្ជ

truemoney
ដាក់ស្រួល ដកស្រួល

ជ្រើសរើស បុគ្គលិក We're hiring




ដោយមានការរីកចម្រើនទៅមុខឥតឈប់ឈរយ៉ាងឆាប់រហ័ស បច្ចុប្បន្ន ក្រុមហ៊ុន ទ្រូម៉ាន់នី កំពុងជ្រើសរើសបុគ្គលិកដែលមានសក្ដានុពល ឆន្ទៈ បុគ្គលិកលក្ខណៈល្អ និងបទពិសោធន៍ ដើម្បីបំពេញការងារតាមតួនាទីដូចខាងក្រោម៖

| No. | Position | Posts | No. | Position | Posts |
|---|---|---|---|---|---|
| 1 | Head of Products | 1 Post | 18 | Corporate Sales Executive | 3 Posts |
| 2 | Head of Corporate Sales | 1 Post | 19 | Payroll Trainer | 1 Post |
| 3 | Customer Relationship Manager | 1 Post | 20 | Digital Marketing Officer | 1 Post |
| 4 | Payroll Manager | 1 Post | 21 | Marketing Executive (MarCom) | 1 Post |
| 5 | Regional Sales Manager | 2 Posts | 22 | Marketing Executive (Event) | 1 Post |
| 6 | Sales Support Manager | 1 Post | 23 | Activation Team Leader | 1 Post |
| 7 | Retail Sales Manager | 1 Post | 24 | Sales Executive | 15 Posts |
| 8 | Training Supervisor | 1 Post | 25 | Care Center Officer | 5 Posts |
| 9 | Sales Supervisor | 6 Posts | 26 | Network Engineering | 1 Post |
| 10 | Sales Support Supervisor | 1 Post | 27 | Technical Support | 2 Posts |
| 11 | Senior Sales Support Officer | 1 Post | 28 | Procurement Officer | 1 Post |
| 12 | Senior Core Developer | 1 Post | 29 | Administrative Officer | 1 Post |
| 13 | Sales Support Officer | 3 Posts | 30 | Customer Service Officer | 2 Posts |
| 14 | Quality Assurance Officer | 1 Post | 31 | Top Up Officer | 3 Posts |
| 15 | Fraud Management Officer | 1 Post | 32 | Activation Officer | 4 Posts |
| 16 | Dispute Officer | 2 Posts | 33 | Receptionist | 1 Post |
| 17 | Risk Management Officer | 1 Post | 34 | Calling Team | 2 Posts |

ព័ត៌មានលំអិត:

016 777 983 | jobs@truemoney.com.kh | www.truemoney.com.kh/vacancies

BIDC
Be your side, by your hand

## BANK FOR INVESTEMENT AND DEVELOPMENT OF CAMBODIA PLC.

-----o0o-----

## KINGDOM OF CAMBODIA
## Nation – Religion – King

-----oo-----

Phnom Penh, 30 November, 2016

## ANNOUNCEMENT

(On launching the Lucky Deposit Promotion Program: "Save to Win")

Bank for Investment and Development of Cambodia Plc., have the honor to formally announce the launching of the Lucky Deposit Promotion program "Save to Win", implemented at BIDC Head Office and all branches in Cambodia with following specific contents:

### I. PROGRAM CONTENTS:

1. Program name, Validity, Locations, requirement:
- Program name: Lucky Deposit Program "Save – to – Win".
- Type of promotion (Regulate by BIDC): Customer joining "Save – to – Win" by open Fixed Deposit (USD) terms of 6, 9, 12, 18, 24 months with interest paid at maturity and will receive lucky draw code to stand a chance to winning the program prizes. Massive prize lucky draw award at the end of the program with total prize award up to equivalent 42,000USD in cash value.
- Promotion period: from 01/December/2016 to 31/March/2017.
- Promotion locations: implemented at BIDC Head Office and its branches in Cambodia.

2. Target Customer:
- Cambodian Individual.
- Foreigner Individual who are living and doing legal business in Cambodia.

### II. PROGRAM PRIZES:

| No. | Prize | Quantity | Value (USD) | Type of Prize | Total value(USD) |
|---|---|---|---|---|---|
| 1 | The Special | 1 | 30,000 | Ford Fiesta 2016 | 30,000 |
| 2 | The First | 1 | 2,500 | Honda Click I125 – Serie 2016 | 2,500 |
| 3 | The Second | 3 | 1,000 | Iphone 7 Plus 128GB | 3,000 |
| 4 | The Third | 5 | 700 | TV Samsung Smart TV 43" | 3,500 |
| 5 | Bonus Prize | 10 | 300 | Fridge Hitachi 203L Inverter | 3,000 |
| | Total | 20 | | | 42,000 |

### III. PROGRAM INTEREST RATE:

| No. | Term | Currency | Interest rate (%/year) |
|---|---|---|---|
| 1 | 6 months | USD | 4,25% |
| 2 | 9 months | USD | 4,50% |
| 3 | 12 months | USD | 5,25% |
| 4 | 18 months | USD | 5,50% |
| 5 | 24 months | USD | 5,75% |

### IV. CONDITIONS FOR PARTICIPANTING IN THE PROGRAM:

With the minimum deposit under the terms, customers will be provided 01 (one) lucky draw code, detailed as below:

| Term | Minimum deposit amount (USD) | Amount eligible of Lucky Draw |
|---|---|---|
| 6 months | 1,500 | 01 |
| 9 months | 1,200 | 01 |
| 12 months | 700 | 01 |
| 18 months | 500 | 01 |
| 24 months | 300 | 01 |

### V. TERMS AND CONDITIONS:

(Please refer to official of Terms and Condition of the program as attach here with APPENDIX 1 in this announcement or find it at any counter of all BIDC's branches in Cambodia).

### HEAD OFFICE

#370 Monivong, Sangkat Boeng Keng Kang I, Khan Chamkarmon, Phnom-penh, Cambodia

Office : +855 23 210 044 / Fax : +855 23 220 511
Email : info@bidc.com.kh / Websit : www.bidc.com.kh
SWIFT : IDBCKHPP


VATTANAC CAPITAL
A World of Difference
EPICENTER
of
CELEBRATION
@ VATTANAC CAPITAL MALL
SHOPPING FESTIVAL STARTS
2ND DEC, 2016 – 15TH JAN, 2017
* TERMS AND CONDITIONS APPLY.
PRIVILEGE SHOPPING @
Brioni
BOSS HUGO BOSS
Christofle PARIS
Salvatore Ferragamo
LONGCHAMP PARIS
LACOSTE
CLARINS
L'OCCITANE EN PROVENCE
TWG TEA
PETIT BATEAU
PAZZION Fabulously You
RIMOWA Germany since 1898
ERIC KAYSER
FUTUREWORLD
N° 66, PREAH MONIVONG BLVD | +855 (0) 23 938 888
VATTANACCAPITAL.COM
VATTANAC CAPITAL
VATTANACCAPITALMALL